# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិ
រៀបចំបុណ្យជាតិ_អន្តរជាតិ
លេខៈ ០៧/២០១៧ គជបអ

# ផែនការណែនាំ
## ស្តីពីការចាត់តាំងរៀបចំទិវាអក្ខរកម្មជាតិ ០៨ កញ្ញា ឆ្នាំ២០១៧

<u>យោង</u> : ព្រះរាជក្រឹត្យលេខ នស/រកត.០៨០៥/៣៥៤ ចុះថ្ងៃទី ៥ ខែសីហា ឆ្នាំ២០០៥ ស្តីពីការកែសម្រួល **គណៈកម្មការអចិន្ត្រៃយ៍រៀបចំបុណ្យជាតិ-អន្តរជាតិ ទៅជា គណៈកម្មាធិការជាតិរៀបចំបុណ្យជាតិ-អន្តរជាតិ**

-ព្រះរាជក្រឹត្យលេខ នស/រកត/០៩០០/១៦៣ ចុះថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០០០ ស្តីពីការកំណត់យកថ្ងៃទី ០៨ ខែកញ្ញា រៀងរាល់ឆ្នាំជាទិវាអក្ខរកម្មជាតិ។

-សារាចរណែនាំ សម្រាប់អនុវត្តជាអចិន្ត្រៃយ៍លេខ ០៩ សរណន ចុះថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០០៣ របស់រាជរដ្ឋាភិបាល ស្តីពីការរៀបចំចាត់តាំងព្រះរាជពិធីបុណ្យទូទសមាស បុណ្យប្រពៃណីជាតិ ប្រពៃណីសាសនា បុណ្យជាតិ-បុណ្យអន្តរជាតិ។

-សំណើសុំផ្ទេរការរៀបចំទិវាអក្ខរកម្មជាតិ ៨ កញ្ញា លេខ៣១៩០ អយក.អបក របស់ក្រសួងអប់រំ យុវជន និងកីឡា មក គណៈកម្មការអចិន្ត្រៃយ៍រៀបចំបុណ្យជាតិ-អន្តរជាតិ ចុះថ្ងៃទី០៤ ខែវិច្ឆិកា ឆ្នាំ២០០៤

-លិខិតលេខ៣៩៥៩ អយក.អកប ចុះថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៧ របស់ក្រសួងអប់រំយុវជន និងកីឡាស្តីពីការរៀបចំពិធីប្រារព្ធទិវាអក្ខរកម្មជាតិ ០៨ កញ្ញា ឆ្នាំ២០១៦។

ឆ្លើយតបទៅនឹងព្រះរាជក្រឹត្យ សារាចរណែនាំ និងគោលបំណងសំណូមពរ ដែលបានកំណត់យកប្រធានបទ **"អក្ខរកម្មផ្សារភ្ជាប់នឹងសហគមន៍"** និងការប្រគល់ភារកិច្ចដូចខាងលើ **គណៈកម្មាធិការជាតិរៀបចំបុណ្យជាតិ-អន្តរជាតិ** សូមធ្វើការណែនាំដល់ក្រសួង រដ្ឋលេខាធិការដ្ឋាន ស្ថាប័ន រាជធានី និងគ្រប់ខេត្ត រួមសហការអនុវត្តឲ្យទទួលបានលទ្ធផលល្អប្រសើរ នូវភារកិច្ចដូចខាងក្រោម ៖

**១- ក្រសួងអប់រំ យុវជន និងកីឡា** រៀបចំសារមួយសម្រាប់ថ្នាក់ដឹកនាំជាន់ខ្ពស់ជាតិ ផ្សព្វផ្សាយតាមវិទ្យុ ទូរទស្សន៍ជាតិ និងឯកជន អបអរសាទរទិវានេះ ដោយមានខ្លឹមសារគ្រប់ជ្រុងជ្រោយ ព្រមទាំងសហការជាមួយខេត្តបាត់ដំបង រៀបចំប្រារព្ធទិវាអក្ខរកម្មជាតិ ០៨ កញ្ញា លើកទី១៧ ឆ្នាំ២០១៧ ឲ្យបានមហោឡារិក ។

**២- ក្រសួងធម្មការ និងសាសនា** ត្រូវចាត់តាំងរៀបចំធ្វើអង្គសិក្ខាសាលាមួយ ក្រោមប្រធានបទ **"អក្ខរកម្មផ្សារភ្ជាប់នឹងសហគមន៍"** ដើម្បីបណ្តុះឧបនិស្ស័យ បញ្ញាញាណ ពោលគឺការបង្កើននូវចំណេះដឹងឲ្យបានជ្រាលជ្រៅ ដោយមានការនិមន្ត និងអញ្ជើញចូលរួមពីសំណាក់បព្វជិតពុទ្ធសាសនា ពាហិរសាសនា អាចារ្យ ស៊ីលវន្ត ស៊ីលវតី គណៈកម្មការវត្ត និងសាវ័កនៃពាហិរសាសនា ។

**៣- ក្រសួងព័ត៌មាន** ត្រូវមានកម្មវិធីចុះយកព័ត៌មានតាមកន្លែងប្រារព្ធពិធី ធ្វើបទអត្ថាធិប្បាយ បទយកការណ៍ ស្តីពីការងារអប់រំក្រៅប្រព័ន្ធនៅកម្ពុជា ផ្សព្វផ្សាយតាមវិទ្យុ ទូរទស្សន៍ជាតិ និងឯកជន ឲ្យបានទូលំទូលាយ ដើម្បីអប់រំបំផុសចលនាឲ្យឃើញថា អក្ខរកម្ម គឺជាមូលដ្ឋាននៃការអភិវឌ្ឍប្រទេសជាតិលើគ្រប់វិស័យ ។

[illegible] ០៣៩ លេខ ២៨០ រាជធានីភ្នំពេញ Tel/Fax: (855) 023 986 370 - (855) 023 986 374 - (855) 023 213 956 E-mail: ck01275577@gmail

៤- គ្រប់ក្រសួង រដ្ឋលេខាធិការដ្ឋាន និងស្ថាប័ន ត្រូវរៀបចំតុបតែងលម្អទង់ជាតិ បដាពាក្យស្លោកនៅតាមអង្គភាព ដើម្បីញ៉ាំងឲ្យ ថ្ងៃ០៨ កញ្ញា ជាទិវាអក្ខរកម្មជាតិ មានភាពមហោឡារិកថែមទៀត ។

៥- **រាជធានីភ្នំពេញ និងគ្រប់ខេត្ត** ត្រូវចាត់ចែងរៀបចំ ៖

-ចងទង់ជាតិ បដាពាក្យស្លោក គ្រប់មន្ទីរ អង្គភាព ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ គ្រប់វត្តអារាម អគារសាធារណៈ ក្រុមហ៊ុន រោងចក្រ សហគ្រាស សាលារៀន ទីប្រជុំជន លំនៅដ្ឋានប្រជាពលរដ្ឋ តាមដងផ្លូវសាធារណៈ ឲ្យបានព្រមៗគ្នា។

-ចាត់តាំងធ្វើមីទីញ ឬប្រជុំហែក្បួន ដែលមានខ្លឹមសារពាក់ព័ន្ធទៅនឹងការឧបត្ថម្ភគាំទ្រ និងលើកទឹកចិត្តដល់ចលនាអក្ខរកម្ម ដែលជាកូនសោក្នុងការអភិវឌ្ឍខ្លួនឯង គ្រួសារ សហគមន៍ និងប្រទេសជាតិទាំងមូល ។

-សហការជាមួយបណ្តាអង្គការនានា ដែលធ្វើសកម្មភាពផ្នែកអប់រំក្រៅប្រព័ន្ធ ដើម្បីរៀបចំពិព័រណ៍បង្ហាញអំពីសកម្មភាព និងលទ្ធផលនៃការងារអប់រំក្រៅប្រព័ន្ធក្នុងឆ្នាំកន្លងមក។

-បំផុសចលនា និងធ្វើការប្រឡងជ្រើសរើសសិស្សអក្ខរកម្មពូកែ ដោយយកចិត្តទុកដាក់ បេក្ខជន បេក្ខនារី ដែលទទួលបានពិន្ទុល្អ នឹងត្រូវបានជូនរង្វាន់លើកទឹកចិត្តតាមលទ្ធភាពរាជធានី ខេត្ត និងមូលដ្ឋាននីមួយៗ។ ចំពោះទីកន្លែងពុំទាន់មានថ្នាក់រៀនអក្ខរកម្ម ត្រូវចាត់តាំងមន្ត្រីជំនាញចុះទៅឃោសនា អំពីសារសំខាន់នៃការរៀនសូត្រ ដែលជាមូលដ្ឋានគ្រឹះនៃការអប់រំ។

-ត្រូវជ្រើសរើសរូបមន្ត និងពិធីសាស្ត្របង្រៀនដល់អ្នកដែលពុំអាចរៀនអក្សរកើត ដោយការប្រើប្រាស់រូបភាពជាក់ស្តែង តាមរយៈសម្ភារ បរិក្ខារ ប្រើប្រាស់ប្រចាំថ្ងៃ រួមទាំងលេខនព្វន្ត បូក សង គុណ ចែក ជាឧទាហរណ៍ និងតម្រូវឲ្យអនក្ខរជនម្នាក់ៗ ហ្វឹកហាត់ធ្វើដោយផ្ទាល់។

-អំពាវនាវដល់អង្គការជាតិ អង្គការអន្តរជាតិ ផ្នែកឯកជននិងសាធារណជនទូទៅ ឲ្យចូលរួមជួយគាំទ្រដល់សកម្មភាពនៃទិវាអក្ខរកម្មជាតិ ០៨ កញ្ញា ក្នុងតំបន់រៀងៗខ្លួន សំដៅធ្វើយ៉ាងណាឲ្យទិវានេះមានសភាពផុលផុស និងមហោឡារិក។

៦- **គណៈកម្មាធិការជាតិអប់រំសម្រាប់ទាំងអស់គ្នា** នៅគ្រប់លំដាប់ថ្នាក់ ត្រូវប្រជុំរៀនសូត្រអំពីគោលនយោបាយ នៃការងារអប់រំក្រៅប្រព័ន្ធតាមសភាពជាក់ស្តែង តាមឋានានុក្រមនីមួយៗ។

៧- **អង្គការជាតិ អង្គការអន្តរជាតិ ផ្នែកឯកជន និងសាធារណជន** សូមចូលរួមជួយសហការគាំទ្រទិវានេះ ឲ្យបានខ្លាំងក្លានៅតាមទីកន្លែង និងតាមលទ្ធភាពរបស់ខ្លួន ។

៨- **ទីស្តីការគណៈរដ្ឋមន្ត្រី និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ** ត្រៀមលក្ខណៈដោះស្រាយសម្ភារ ថវិកា ជូនដល់ក្រសួង ស្ថាប័នពាក់ព័ន្ធ ដែលត្រូវចំណាយចំពោះមុខជាក់ស្តែងចាំបាច់ សម្រាប់បម្រើទិវាដ៏មានសារសំខាន់នេះ ឲ្យបានសមស្រប និងទាន់ពេលវេលា ។

គណៈកម្មាធិការជាតិរៀបចំបុណ្យជាតិ-អន្តរជាតិ សង្ឃឹមថាគ្រប់ក្រសួង រដ្ឋលេខាធិការដ្ឋាន ស្ថាប័ន រាជធានី និងគ្រប់ខេត្ត ទទួលបានផែនការណែនាំនេះ នឹងយកស្មារតីទទួលខុសត្រូវ ខិតខំសហការចាត់តាំងអនុវត្តឲ្យទទួលបានលទ្ធផលល្អប្រសើរ សមស្របតាមគោលបំណង នៃប្រធានបទ និងសំណូមពររបស់រាជរដ្ឋាភិបាល ។

រាជធានីភ្នំពេញ ថ្ងៃទី ០[illegible] ខែ[illegible] ឆ្នាំ២០១៧

ជ.**គណៈកម្មាធិការជាតិរៀបចំបុណ្យជាតិ-អន្តរជាតិ**

**ប្រធាន**

**សម្តេចចៅហ្វាវាំង ចរឡើងជ័យ អធិបតីស្រីថ្ការ គង់ សំអុល**

<u>**កន្លែងទទួល**</u>

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម ឧបនាយករដ្ឋមន្ត្រីប្រចាំការ

"ដើម្បីជូនជ្រាប"

- គ្រប់ក្រសួង រដ្ឋលេខាធិការដ្ឋាន ស្ថាប័ន រាជធានី និងគ្រប់ខេត្ត

"ដើម្បីសហការអនុវត្ត"

- ឯកសារ-កាលប្បវត្តិ

# ពាក្យស្លោក

## ស្តីពីការចាត់តាំងរៀបចំទិវាអក្ខរកម្មជាតិ ០៨ កញ្ញា ឆ្នាំ២០១៧

១- ជ័យោ! ព្រះរាជាណាចក្រកម្ពុជា

២- ជាតិ សាសនា ព្រះមហាក្សត្រ

៣- អបអរសាទរ ទិវាអក្ខរកម្មជាតិ ០៨ កញ្ញា

៤- រៀនហើយ រៀនទៀត រៀនពេញមួយជីវិត

៥- អប់រំសម្រាប់ទាំងអស់គ្នា ទាំងអស់គ្នាដើម្បីការអប់រំ

៦- រៀនដើម្បីអភិវឌ្ឍខ្លួនឯង គ្រួសារ និងសង្គមជាតិ

៧- អក្ខរកម្ម ជាពន្លឺនៃសុខមង្គល

៨- អក្ខរកម្ម ជាគន្លឹះនៃការអភិវឌ្ឍ

៩- អក្ខរកម្មរួមចំណែកកាត់បន្ថយភាពក្រីក្រ

១០- អក្ខរកម្មទប់ស្កាត់អេដស៍

១១- អក្ខរកម្មទប់ស្កាត់ការកេងប្រវ័ញ្ចពលកម្មកុមារ

១២- អក្ខរកម្មទប់ស្កាត់ការប្រើប្រាស់គ្រឿងញៀន

១៣- អក្ខរកម្មជាមធ្យោបាយបំបាត់អំពើហិង្សា

១៤- មានអក្ខរកម្ម មានចំណេះដឹង មានការអភិវឌ្ឍ

១៥- អក្ខរកម្មជាមូលដ្ឋាននៃការសិក្សាពេញមួយជីវិត

១៦- អក្ខរកម្មគឺជាគ្រឹះនៃចំណេះដឹង

១៧- អក្ខរកម្មជាគ្រឹះនៃការអប់រំ

១៨- អក្ខរកម្មជំរុញការអភិវឌ្ឍ

១៩- អក្ខរកម្មគឺជាសិទ្ធិមូលដ្ឋាន

២០- អក្ខរកម្ម ជាមូលដ្ឋាននៃការអភិវឌ្ឍ

២១- អក្ខរកម្មរួមចំណែកអភិវឌ្ឍសហគមន៍

២២- អក្ខរកម្ម ធ្វើឲ្យជីវភាពរស់នៅកាន់តែប្រសើរឡើង

២៣- អក្ខរកម្មរួមចំណែកកាត់បន្ថយចំណាកស្រុកដោយប្រថុយប្រថាន

២៤- អក្ខរកម្មជួយបង្កើនសេដ្ឋកិច្ចគ្រួសារ

២៥- អក្ខរកម្មផ្សារភ្ជាប់នឹងសហគមន៍